**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

# សារលិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**បរពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លា នៃព្រះរាជពិធីខួបលើកទី១៦ ការយាងគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទូលព្រះបង្គំយើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវអំណរសាទរយ៉ាងក្រៃលែង ប្រកបដោយស្មារតីកក្តីដ៏ជ្រាលជ្រៅជាទីបំផុត ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង**។

ទូលព្រះបង្គំយើងខ្ញុំ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវមនោសញ្ចេតនាប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុត ចំពោះព្រះមហាករុណាទិគុណរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ដែលព្រះអង្គតែងបានយកអស់កម្លាំងព្រះកាយពល និងព្រះបញ្ញាញាណមិនខ្លាចនឿយហត់ បំពេញព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជារាស្ត្រជាទីស្រលាញ់របស់ព្រះអង្គ។ ក្រោមព្រះរាជសម្បត្តិដ៏ត្រជាក់ត្រជុំថ្លៃថ្លាមិនអាចកាត់ថ្លៃបាន និងព្រះមហាករុណាទិគុណប្រកបដោយទសពិធរាជធម៌ដ៏ប្រពៃរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់បានជ្រកក្រោមម្លប់ដ៏សុខដុមនៃសន្តិភាព ស្ថេរភាព ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។

នាឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លានេះ ទូលបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ សូមធ្វើអភិវន្ទនកិច្ចថ្វាយព្រះពរបវរមហាប្រសើរ និងសូមលើកហត្ថទាំងទ្វេប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាព្រះមហាស្វេតច្ឆ័ត្រ សូមតាមបីបាច់ថែរក្សា ប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** សូម **ព្រះអង្គទ្រង់**ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ច និងព្រះសេយ្យកក្តីដ៏ស្មោះស្ម័គ្របំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។ ល

ថ្ងៃ អង្គារ ១១ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ព្រុំ សុខា**